ព្រះ យើងត្រូវជឿដល់ព្រះយេស៊ូវគ្រីស្ទ ។

## ២. ការប្រលងនេះមានសំនួរតែមួយ

ការប្រលងនេះមានសំនួរតែមួយ ហើយនឹងសំនួរនេះយើងដឹងហើយ តើប្អូនៗចូលចិត្ត ដឹង សំនួរមុនពេលប្រលង ឬទេ បើសិនជា ប្អូនៗបានដឹងសំនួរទាំងអស់មុនពេលប្រលង នោះខ្ញុំគិតថាប្អូនៗអាច ប្រលងជាប់ជាប្រាកដ មែនទេ ? ពេលយើងឈរខាងមុខព្រះ នៅពេល នោះមានសំនួរតែមួយ ។

"តើអ្នកដែលទទួលជឿព្រះយេស៊ូវ ឬទេ"?

យ៉ូហាន ៣:៣៦ ថា "ឯអ្នកណាដែលជឿលើព្រះរាជបុត្រានោះ មានជីវិតអស់កល្បជានិច្ចហើយ
តែបើអ្នកណាដែលមិនជឿដល់ព្រះរាជបុត្រាវិញ
នោះមិនឃើញជីវិតសោះឡើយ គឺសេចក្តីក្រោធរបស់ព្រះ
តែងនៅជាប់លើអ្នកនោះឯង " ។

ពេលណាយើងជួបការប្រលង ចុងបំផុតនោះ
យើងមិនបាច់ធ្លាក់ទេ យើងគួរតែរៀបចំខ្លួនថ្ងៃនេះ
ដោយជឿដល់ព្រះយេស៊ូវ ដើម្បីឱ្យយើងឡើងទៅឋានសួគ៌
ក្រោយពីយើងស្លាប់ទៅ ។


ការិយាល័យ សំរាប់ទាក់ទង
ប្រអប់ ប្រៃសណីយ៍ ២៥០៦
ភ្នំពេញ ៣


# កុំភ្លេច អំពីការប្រលង




# ដ៏ធំ!

បាទ.. បន្ទិចទៀតមានការប្រលងដ៏ធំដែលគិតថា ប្អូនៗបានភ្លេចរៀបចំ ។ តើប្អូនៗដែល អង្គុយដើម្បីប្រលង ឬទេ ប៉ុន្តែស្រាប់តែបានដឹង ថា " អូ ! ខ្ញុំភ្លេចរៀបចំហើយ " ? ប្រហែលជាប្អូនៗបានរៀនចំលើ ផ្សេងពីការប្រលង ឬ ប្រហែលជាប្អូនៗអត់រៀនមេរៀនសោះ ។ នេះមិន មែនជាការសប្បាយទេ មែនទេ ? អញ្ចឹងការប្រលងដ៏ធំដែលខ្ញុំកំពុងតែ និយាយគឺមិនដូចការប្រលង ផ្សេងទេ ការប្រលងនេះមិនមែនជាការប្រលងប្រវត្តិសាស្ត្រ ឬ ក្នុងគណិតវិទ្យា ឬ ក្នុងវិទ្យាសាស្ត្រទេ ។ ការប្រលង នេះ គឺការប្រលង ចុងបំផុតក្នុងជីវិតយើង ដើម្បីសំរេចចិត្ត បើយើងនឹង ឡើងទៅឋានសួគ៌ ឬ ធ្លាក់ទៅឋាននរក ។ ក្នុងគម្ពីរហេព្រើរ ៩:២៧ ព្រះអង្គប្រាប់យើងថា " ហើយដោយព្រោះបានដំរូវត្រូវឱ្យមនុស្សទាំងអស់ ស្លាប់មួយដង រួចសឹមជាប់សេចក្តីជំនុំជំរះ "។ ពេលណាយើងឈរខាងមុខ ទីជំនុំជំរះនៃព្រះនោះជាការប្រលងដ៏ធំជាងគេ ។ មនុស្សខ្លះប្រលងជាប់ មានន័យ ថាគេនឹងឡើងទៅឋានសួគ៌ ។ មានមនុស្សផ្សេងគេនឹងប្រលងធ្លាក់ មានន័យថា គេនឹងធ្លាក់ទៅឋាននរក។

១. តើយើងគួរតែរៀបចំសំរាប់ការប្រលង ចុងបំផុតយ៉ាងម៉េច ជាការពិត ទោះបើជាកាប្រលងនេះសំខាន់យ៉ាង ណាក៏ដោយ ក៏ការប្រលងនេះ ងាយស្រួលក្នុងការរៀបចំនឹងងាយស្រួលជាប់ ។

ក. លើកទីមួយយើងត្រូវយល់ថា យើងទាំងអស់គ្នាគឺជាមនុស្សដែលមានបាប ។ រ៉ូម ៣:១០ ថា " គ្មានអ្នកណាសុចរិតសោះ " ព្រះគម្ពីរ ប្រាប់យើងថាគ្រប់គ្នាបានធ្វើបាប មនុស្សចាស់ មនុស្សក្មេង មនុស្សប្រុស មនុស្សស្រី មនុស្សបរទេស មនុស្សខ្មែរ មនុស្សមាននឹងមនុស្សក្រ ក៏ដោយ ។ គ្មាននរណាម្នាក់សុចរិតឡើយ អំពើបាបគឺជាអ្វីដែលយើងធ្វើទៅអាក្រក់ ដូចជា និយាយភូតលួច លួចមើល ស្អប់មនុស្ស គិតគំនិតអាក្រក់ នឹងមិនស្តាប់បង្គាប់ ឪពុកម្តាយ ។

ខ. យើងត្រូវយល់ថាអំពើបាបរបស់យើង ញែកយើងចេញពីព្រះ ព្រះគឺបរិសុទ្ធ នេះមានន័យថា ព្រះមិនដែលធ្វើបាបសោះ ទ្រង់អត់ស្គាល់បាបសោះ ទ្រង់អត់ចេះធ្វើបាបផង ជាការពិតព្រះអង្គស្អប់បាបណាស់ ព្រះស្អប់អំពើបាបដ៏ម្ល៉េះ ដូច្នោះ ទ្រង់មិនឱ្យបាបចូលឋានសួគ៌សោះ ឋានសួគ៌គឺជាកន្លែងដែលព្រះអង្គគង់នៅ ដោយព្រោះ ព្រះអង្គគង់នៅឋានសួគ៌គឺជាកន្លែងបរិសុទ្ធដែរ ដូច្នោះដោយយើង មានអំពើបាប យើងចូលក្នុងឋានសួគ៌មិនបានទេ ។

គ. យើងត្រូវយល់ថា បាបទាំងអស់ត្រូវជាប់មានទោស ។ វិវរណៈ ២១:៨ ថា "តែត្រង់ពួកខ្លាច ពួកមិនជឿ ពួកគួរខ្ពើម ពួកកាប់សំលាប់គេ ពួកកំផិត ពួកមន្តអាគម ពួកថ្វាយបង្គំរូប ព្រះ ហើយទាំងមនុស្សកំភូត គេនឹងមានចំណែកនៅក្នុងបឹងដែល ឆេះជាភ្លើង" ព្រះគម្ពីរថាគ្រប់គ្នា ដែលមានបាបសមនឹងទទួលទោសធ្លាក់ទៅឋាននរកដោយបាបរបស់គេ។ នេះជាដំណឹងអត់ល្អទេ។

## ប៉ុន្តែឥឡូវខ្ញុំមានដំណឹងល្អ !

ឃ. យើងត្រូវយល់ថា ព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាងជំនួសបាបរបស់យើង ។ រ៉ូម ៥:៨ ថា "តែឯព្រះ ទ្រង់សំដែងសេចក្តីស្រឡាញ់ របស់ទ្រង់ដល់យើងរាល់គ្នាឱ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា "។ ព្រះអង្គបានស្រឡាញ់យើងខ្លាំងបានចាត់ព្រះរាជបុត្រានៃទ្រង់ យ៉ាងមកផែនដីនេះ ដើម្បីសុគតជំនួសបាបរបស់យើង ៣ថ្ងៃក្រោយមក ទ្រង់បានរស់ពីស្លាប់ឡើងវិញ ព្រះយេស៊ូវ បានក្លាយជាអ្នក សង្គ្រោះរបស់យើងនឹងបានរៀបចំផ្លូវសំរាប់ទៅឋាន សួគ៌ ។

ង. យើងត្រូវតែអំពាវនាវដល់ព្រះយេស៊ូវ នឹងសូមសេចក្តីសង្គ្រោះពីទ្រង់ ។ ព្រះយេស៊ូវបានសន្យាថាអ្នកណាដែលអំពាវនាវដល់ទ្រង់ នោះ នឹងបានសង្គ្រោះ (រ៉ូម ១០:១៣) ។ ដូច្នោះ បើយើងចង់រៀបចំខ្លួនសំរាប់ការប្រលងចុងបំផុត គឺនៅពេលយើងឈរនៅខាងមុខ